# មនុស្ស

បទបន្ទោលកាក

កំណើតជាមនុស្ស ពិតខុសពីសត្វតិរច្ឆាន
មនុស្សចិត្តកល្យាណ សន្តានចិត្តស្គាល់ខុសត្រូវ ។
វៀរចាកបាបធម៌ អំពើអប្រិយអាស្រូវ
ត្រាច់ត្រង់ត្រឹមត្រូវ សីលប្រាំជាប់នៅតាមកាយ ។
មិនសំលាប់សត្វ មិនស្គាត់លួចទ្រព្យទាំងឡាយ
មិនលួចសប្បាយ រួមកាយប្រពន្ធកូនគេ ។
មិនពោលមុសា វាចាកុហកវៀចវេ
តាំងចិត្តគ្មានគ្មេរ វៀររេចាកគ្រឿងស្រវឹង ។
សារជាតិជាមនុស្ស ត្រូវខុសមនុស្សអាចដឹង
ខិតខំប្រិតប្រឹង ពង្រឹងលើកចិត្តអោយខ្ពស់ ។
ដឹងគុណដឹងគាប់ ទំលាប់រក្សាកេរ្តិ៍ឈ្មោះ
ថែទាំកិត្តិយស ពីរោះទាំងជាតិត្រកូល ។
វៀរចាកអបាយ អោយឆ្ងាយកុំគិតចំណូល
កុំត្រាច់ប្រមូល ចរចូលស្រីស្រាបនល្បែង ។
កុំគប់បាបមិត្ត ជាផ្លូវវងងឹតជាក់ស្តែង
នាំទុក្ខខ្លួនឯង នាំក្តីចំបែងគ្រប់គ្រា ។
នេះជាវិធី ប្រុសស្រីត្រូវចាំគ្រប់គ្នា
កើតលើពសុធា ធ្វើជាមនុស្សពេញលេញ ។

*អូត្តាវ៉ា ថ្ងៃទី ១១ ខែធ្នូ ២០០៥*

*ស្វាត សាលឿម*